**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ១៨១៥ ......... បទ............

"..... ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

# សារាចរណែនាំ
# ស្តីអំពី
# វិធានការទប់ស្កាត់បាតុភាពអសកម្មមួយចំនួនពាក់ព័ន្ធ ជាមួយនឹងអាជីវកម្មសាលអ៊ិនធឺណេតកាហ្វេ

នៅក្នុងព្រះរាជាណាចក្រកម្ពុជាវិស័យបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាន កំពុងរីកចំរើន ទៅតាមបច្ចេកវិទ្យាដ៏ទំនើប បាននឹងកំពុងប្រើប្រាស់ដើម្បីបំរើឲ្យវិស័យទំនាក់ទំនងការងារ សេដ្ឋកិច្ច ការទូត និងបម្រើជីវភាពរស់នៅជាប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ មន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ អ្នកការទូត អ្នកវិនិយោគ ព្រះសង្ឃ និងជនបរទេស មានជាអាទិ៍៖ ទូរស័ព្ទចល័ត ទូរស័ព្ទអចល័ត ទូរសារ អ៊ីនធឺណេត និង ប្រព័ន្ធសំលេងតាមអ៊ីនធឺណេតគ្រប់ប្រភេទ......។ល។

តាមបទពិសោធន៍ក្នុងការស្រាវជ្រាវបង្ក្រាបបទល្មើសនានាកន្លងមករបស់ក្រសួង និង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ បានកត់សំគាល់ឲ្យឃើញថា៖ មានជនឧក្រិដ្ឋជននិងជនទុច្ចរិត បានប្រើប្រាស់មធ្យោបាយតាមបច្ចេកវិទ្យាទូរគមនាគមន៍ ដើម្បីធ្វើសកម្មភាពភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន អំពើឆក់ប្លន់ ចាប់ជំរិតទារប្រាក់ អំពើឃាតកម្ម ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស បទល្មើសសេដ្ឋកិច្ច លួចតម្លើងនិងធ្វើអាជីវកម្មលើប្រព័ន្ធទូរគមនាគមន៍ខុសច្បាប់គ្រប់រូបភាព ការបញ្ជូនផ្សព្វផ្សាយរូបភាពអាសអាភាស និងអំពើអនាចារផ្សេងៗទៀត ដែលធ្វើឲ្យប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃណីដ៏ល្អ និងសីលធម៌សង្គម។

និងជាពិសេសទៅទៀតនោះដោយពិនិត្យឃើញថា ក្នុងរយៈពេលកន្លងទៅនេះ បានកើតមាននូវបាតុភាពអវិជ្ជមានមួយចំនួន ដែល ជះឥទ្ធិពលមិនល្អ ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋទូទៅ ជាពិសេសអាណាព្យាបាលសិស្ស ដោយសារកូន របស់ពួកគាត់មួយចំនួនតូចវក់នឹងល្បែងហ្គេម និង រូបភាពអាសអាភាស តាម រយៈអ៊ិនធឺណេត រហូតដល់ពេលខ្លះគេចវេះសាលា មិនចូលរៀន ហ៊ានលួចលុយកាក់របស់ឪពុក ម្តាយ អាណាព្យាបាល ព្រមទាំងលែងចង់ស្តាប់ដំបូន្មានរបស់លោកគ្រូ អ្នកគ្រូទៀតផង។/

ដើម្បីលុបបំបាត់បាតុភាពអសកម្មដូចបានពោលខាងលើ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានកិត្តិយសសូមជូនដំណឹងដល់គ្រប់បណ្តាប្រតិបត្តិករ ក្រុមហ៊ុនចំរុះរដ្ឋ និងក្រុមហ៊ុនឯកជន ព្រមទាំងសាខាចែកចាយបន្តទាំងអស់ និងម្ចាស់អាជីវកម្មសាលបំពីសេវាអ៊ិនធឺណេតកាហ្វេទាំងអស់ ដែលកំពុង និង ត្រៀមបើកអាជីវកម្មរបស់ខ្លួន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមការណែនាំដូចខាងក្រោម៖

១. សាលបំពីសេវាអ៊ិនធឺណេតកាហ្វេទាំងឡាយណា ដែលបាននិងកំពុងត្រៀមដាក់ទីតាំងរបស់ខ្លួននៅ ជិតគ្រឹះស្ថានសិស្សានិងសាលារៀន ត្រូវរុះរើប្តូរទីតាំងទៅរកកន្លែងថ្មី ក្នុងចំងាយយ៉ាងតិច ៥០០ម៉ែត្រ (ប្រាំរយម៉ែត្រ) ពីគ្រឹះស្ថានសិក្សានិងសាលារៀន ដើម្បីកុំឲ្យមានការរំខានដល់ការសិក្សារបស់សិស្សានុសិស្ស។

២. មិនអនុញ្ញាតឲ្យយកសាលបំពីអ៊ិនធឺណេតកាហ្វេ ទៅប្រើប្រាស់ធ្វើជាកន្លែងលេងល្បែងហ្គេមគ្រប់ប្រភេទ ជាពិសេសល្បែងហ្គេមទាំងឡាយណាដែលមានលក្ខណៈជា ល្បែងស៊ីសងដូចជាការភ្នាល់បាល់ ចាក់កន្ទុយលេខ ដែលជាការហាមឃាត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៣. ហាមយកទីតាំងសាលបំពីសេវាអ៊ិនធឺណេតកាហ្វេ សម្រាប់អនុញ្ញាតឲ្យភ្ញៀវឆែកមើលវិបសាយអាសអាភាសគ្រប់ប្រភេទ ដែលជាបុព្វហេតុជំរុញឲ្យកើតមាននូវបទល្មើសផ្សេងៗ ដូចជាការចាប់រំលោភសេពសន្ថវៈ និង អពើហឹង្សាក្នុងគ្រួសារជាដើម ដែលធ្វើឲ្យបាត់បង់នូវសេចក្តីថ្លៃថ្នូរសង្គម និងធ្វើឲ្យប៉ះពាល់ដល់ទំនៀមទំលាប់និងប្រពៃណីដ៏ល្អផូរផង់របស់ជាតិ។

៤. ហាមដាច់ខាត ការយកទីតាំងសាលបំពីសេវាអ៊ិនធឺណេតកាហ្វេ ធ្វើជាកន្លែងប្រើប្រាស់ ចរាចរ និងជួញដូរគ្រឿងញៀនគ្រប់ប្រភេទ និងធ្វើជាកន្លែងប្រព្រឹត្តអំពើឧក្រិដ្ឋដទៃទៀតដូចជាការចាប់ជម្រិតមនុស្សឆ្លងដែន លាងលុយកខ្វក់ និងការជួញដូរផ្លូវភេទឆ្លងដែនជាដើម ដែលហេតុបង្កឲ្យមានផលប៉ះពាល់ច្រើយ៉ាងដល់ សុខភាព សុវត្ថិភាព និងសន្តិសុខសង្គម ព្រមទាំងជះឥទ្ធិពលមិនល្អដល់កិត្តិយស និងកិត្យានុភាពសង្គមជាតិទៀតផង។

បញ្ញត្តិករទូរគមនាគមន៍កម្ពុជា គ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត-ក្រុង សាលាខេត្ត-ក្រុង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ និងកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងម្ចាស់បើកសាលបំពីសេវាអ៊ិនធឺណេតកាហ្វេទាំងអស់ ត្រូវសហការអនុវត្តនូវខ្លឹមសារនៃសារាចរណ៍នេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងករណីមាន ម្ចាស់សាលបំពីសេវាអ៊ិនធឺណេតកាហ្វេណា មិនព្រមអនុវត្តតាមសេចក្តីប្រកាសនេះទេ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងសហការជាមួយស្ថាប័នច្បាប់ ព្រមទាំងសមត្ថកិច្ចពាក់ព័ន្ធ នឹងចាត់វិធានការចុះបង្ក្រាប និងរឹបអូសយកសម្ភារៈបរិក្ខារ ព្រមទាំងឃាត់ខ្លួនម្ចាស់សាលបំពីអ៊ិនធឺណេតដែលប្រព្រឹត្តល្មើស បញ្ជូនទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន។ /ㄹ.

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សង្ឃឹមយ៉ាងមុតមាំថា បងប្អូនអាជីវករទាំងអស់ដែលជាម្ចាស់សាលបំរើអ៊ិនធឺណេតកាហ្វេ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា នឹងចូលរួមសហការ អនុវត្តនូវខ្លឹមសារនៃសារាចរណ៍នេះ ដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០១២

**រដ្ឋមន្ត្រី**

**ស៊ូរ-ឃុន**

**កន្លែងទទួល**

- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងអប់រំ យុវជន និង កីឡា
- គ្រប់សាលាខេត្ត-ក្រុង

**"ដើម្បីជូនជ្រាប"**

- បញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- គ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត-ក្រុង
- ម្ចាស់សាលបំរើសេវាអ៊ិនធឺណេតកាហ្វេទូទាំងព្រះរាជាណាចក្រកម្ពុជា

**"ដើម្បីសហការអនុវត្ត"**

- ឯកសារ-កាលប្បវត្តិ